ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ :...៧០០...........បទ.ប្រក.

"...ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព"

ភ្នំពេញ ,ថ្ងៃទី១៧ ខែសីហា ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពីការ កែសម្រួល និងបន្ថែមលើការគ្រប់គ្រង បរិក្ខារវិទ្យុគមនាគមន៍ និង ថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ

~~~~~~~~~~~~

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និង ការ ប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ០៥ អ.ន.ក្រ ចុះថ្ងៃទី០៥ ខែមិនា ឆ្នាំ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពី ប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការ ប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០០២ ស្តីពីការកែសម្រួល និង បំពេញបន្ថែមនាយកដ្ឋានមួយចំនួន នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ/បក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៣ ស្តីពីការតម្លើងនាយកដ្ឋាន រដ្ឋបាល និងបណ្តុះបណ្តាល ទៅជាអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
~~~~~~~~~~~~

- បានឃើញសេចក្តីសម្រេចលេខ ១៩៤ សសរ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីឋានានុក្រម គ្រប់គ្រងតម្លៃ
- ប្រកាសលេខ ២៧២ បទ.ប្រក ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងបរិក្ខារវិទ្យុគមនាគមន៍ និង ថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ
- យោងតាមការងារចាំបាច់របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## **សំរេច**

**ប្រការ១ :** ត្រូវបានបន្ថែម និងកែសម្រួលថ្លៃប្រើប្រាស់រលកអាកាសវិទ្យុក្នុង **ឧបសម្ព័ន្ធទី១** ចំណុចទី៨ និងឧបសម្ព័ន្ធទី២ នៃប្រកាសលេខ ២៧២ បទ.ប្រក ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៣ ស្តីពីថ្លៃនៃការប្រើប្រាស់បរិក្ខារ ទំនាក់ទំនងអន្តរជាតិ (ក្នុងករណីមានការអនុញ្ញាតពិសេស) ត្រូវបន្ថែម និងកែសម្រួលមានដូចជា:

**I-ឧបសម្ព័ន្ធទី១: ថ្លៃប្រើប្រាស់រលកអាកាសវិទ្យុ " បន្ថែម "**

| | |
|---|---|
| **ឃ/ VSAT សំរាប់សម្លេង/ទិន្នន័យលេខ (សំរាប់ក្រុមហ៊ុនទូរស័ព្ទ)** | $ |
| -ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនិមួយៗ | ៥០ |
| -ការពិនិត្យឋបនកណ្ឌមួយគ្រឿងៗ មុនពេលតម្លើង | ១០០ |
| -តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់ស្ថានីយ៍មួយគ្រឿងៗ | ២.០០០ |
| **ង/ VSAT សំរាប់បញ្ជូនរូបភាពទូរទស្សន៍ក្នុងប្រទេស** | $ |
| -ការទទួលពិនិត្យពាក្យសុំប្រើប្រាស់បរិក្ខារនិមួយៗ | ៥០ |
| -ការពិនិត្យឋបនកណ្ឌមួយគ្រឿងៗ មុនពេលតម្លើង | ១០០ |
| -តម្លៃអាជ្ញាប័ណ្ណប្រចាំឆ្នាំ សំរាប់ស្ថានីយ៍មួយគ្រឿងៗ | ១.០០០ |

**II-ឧបសម្ព័ន្ធទី២: ការទទួលស្គាល់បរិក្ខារវិទ្យុទូរគមនាគមន៍** (Type Approval Per Model) " **កែសម្រួល** "

| | | |
|---|---|---|
| -ទូរស័ព្ទចល័ត | ២.០០០ | (one time only) |
| -ទូរសារ (Facsimile machine) | ១.៥០០ | (one time only) |
| -បមាណី (PABX) | ១.៥០០ | (one time only) |
| -ទូរស័ព្ទធម្មតា ឬ Wireless Phone | ១.៥០០ | (one time only) |
| -ផេជឺង (Pager) | ១.០០០ | (one time only) |
| -បរិក្ខារវិទ្យុគមនាគមន៍ដទៃផ្សេងទៀត | ១.០០០ | (one time only) |
| -ប្រកាសទទួលស្គាល់ភ្នាក់ងារនាំចូលបរិក្ខារវិទ្យុគមនាគមន៍ | ៨០០ | (one time only) |
| -លិខិតនាំចូលបរិក្ខារវិទ្យុគមនាគមន៍ | ១០០ | (each time) |
| -វិញ្ញាបនប័ត្រប្រចាំឆ្នាំសំរាប់នាំចូល លក់ និង ជួសជុលបរិក្ខារវិទ្យុគមនាគមន៍ | ១០០ | |
| -វិញ្ញាបនប័ត្រប្រចាំឆ្នាំសំរាប់នាំចូល និង លក់ បរិក្ខារវិទ្យុគមនាគមន៍ | ៨០ | |
| -វិញ្ញាបនប័ត្រប្រចាំឆ្នាំសំរាប់លក់ និង ជួសជុលបរិក្ខារវិទ្យុគមនាគមន៍ | ៥០ | |

**ប្រការ២ :** ប្រកាសលេខ២៧២ បទ.ប្រក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៣ នៅមានតម្លៃជាធរមាន ។

**ប្រការ៣ :** អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ គ្រប់នាយកដ្ឋានពាក់ព័ន្ធ និងគ្រប់មន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ ខេត្ត-ក្រុង ក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៤ :** ប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ស្ទួរ-ឃុន

**<u>កន្លែងទទួល</u>**

-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋាន រដ្ឋសភា
-ទីស្តីការ គណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងផែនការ
-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៣ " ដើម្បីអនុវត្ត "
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ